**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខៈ ០០៤/១៦ សរ.ព.ព.ពបហ

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**
**ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦**

នៅព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ ២០១៦ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងច្បាប់ ស្តីពីយុត្តិធម៌អនីតិជន។**

**២- សេចក្តីព្រាងផែនការមេឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣ (២០១៦-២០២៣)។**

**៣- បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ «កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលហុងគ្រី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័តៈ

## ១- សេចក្តីព្រាងច្បាប់ ស្តីពីយុត្តិធម៌អនីតិជន

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានរៀបចំឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដោយអនុលោមតាម៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រាទី៤៨ ដែលបានចែងថា "រដ្ឋធានាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ" ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើអោយខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំអោយអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។
- អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីការលើកស្ទួយសិទ្ធិកុមារ

- កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តោតទៅលើកម្មវិធីកំណែទម្រង់អាទិភាពបួនយ៉ាង ដែលក្នុងនោះមានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អានីតិជនមាន១៦ជំពូក និង៨៩មាត្រា មានសារៈសំខាន់ក្នុងការបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានចក្ខុវិស័យ និងគោលដៅ៖

- ការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ រួមទាំងការពារប្រយោជន៍របស់ជនរងគ្រោះ សហគមន៍ និងសង្គម
- បង្កើននូវការអប់រំ ទប់ស្កាត់ និងកាត់បន្ថយភាពអសកម្មផ្សេងៗ ក្នុងជួរអនីតិជន ឆ្លើយតបទៅនឹងវិធានការដែលរាជរដ្ឋាភិបាល រួមជាមួយគ្រួសារ សហគមន៍ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងការអភិវឌ្ឍអនីតិជនឲ្យក្លាយជាពលរដ្ឋល្អ និងជាអ្នកបន្តវេនរបស់ប្រទេសជាតិ
- បង្កើនកិច្ចសហការរវាងក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការនីតិប្រតិបត្តិ និងតុលាការក្នុងការដោះស្រាយបញ្ហាអនីតិជនឲ្យស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ
- បំពេញកាតព្វកិច្ចជាប្រទេសសមាជិកនៃអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយស្ថាប័នអន្តរជាតិផ្សេងៗក្នុងការការពារសិទ្ធិកុមារ។

## ២- សេចក្តីព្រាងផែនការមេឆ្នោះទៅធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ី អាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣ (២០១៦-២០២៣)។

កម្ពុជាឆ្លងកាត់សោកនាដកម្មនៃសង្គ្រាមធ្វើឲ្យវិស័យកីឡា ក៏ដូចវិស័យដទៃទៀតធ្លាក់ចុះក្រោមសូន្យ។ ក្រោមពន្លឺនៃសន្តិភាព និងស្ថិរភាពនយោបាយ ដែលទទួលបានដោយនយោបាយ ឈ្នះ-ឈ្នះ និងការដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានធ្វើឲ្យកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ទទួលបាន ៧,៧% ក្នុងរយៈពេលពីរទសវត្សចុងក្រោយ ធ្វើឲ្យវិស័យកីឡាកម្ពុជាស្ទុះផុសផុល រីកចម្រើន និងទទួលបានការគាំទ្រពីយុវជន និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ហើយថែមទាំងដណ្តើមបានជ័យលាភីជាបន្តបន្ទាប់ ធ្វើឲ្យកេរ្តិ៍ឈ្មោះ និងកិត្យានុភាពល្បីសុះសាយលើឆាកអន្តរជាតិ។

ដោយមើលឃើញពីការរីកចម្រើននៃវិស័យកីឡាកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានឯកភាព និងយល់ព្រមអនុញ្ញាតជាគោលការណ៍ឲ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាទទួលធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) នៅឆ្នាំ២០២៣។

តបតាមលិខិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី លេខ២១L.I ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ផ្ញើជូនប្រធានក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ដែលក្នុងនោះក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ បានប្រគល់លិខិតចាត់តាំង ឲ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣។

ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣ នឹងបង្ហាញមុខមាត់កម្ពុជាថ្មីពី (GDP) ចំណូលមធ្យមកំរិតទាប ទៅ(GDP) ចំណូលកំរិតមធ្យម និងដណ្ដើមឧត្តមភាពកីឡាអាស៊ីអាគ្នេយ៍ (SEA Games) ឆ្នាំ ២០២៣ នៅទីក្រុងភ្នំពេញព្រះរាជាណាចក្រកម្ពុជា។ ធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានសក្ដានុពលទេសចរណ៍វប្បធម៌ នយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។

កីឡាអាស៊ីអាគ្នេយ៍ (SEA Games ) លើកទី៣២នៅព្រះរាជាណាចក្រកម្ពុជា នឹងប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ និងបណ្ដាខេត្តមួយចំនួន (កំពត កែប តាកែវ សៀមរាប បាត់ដំបង និងកំពង់ចាម) ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២៣ ដែលរំពឹងថា នឹងមានអ្នកចូលរួមសរុបប្រមាណ១០ ០០០នាក់ ក្នុងនោះមានកីឡាករ ប្រមាណ ៧០០០នាក់ រួមជាមួយមន្ត្រី ប្រតិភូអម ភ្ញៀវអង្គការកីឡា និងភ្ញៀវឥស្សរជនជាន់ខ្ពស់ ដូចជាក្រុមគ្រួសារចលនាអូឡាំពិក ប្រតិភូគណៈកម្មាធិការអូឡាំពិកអន្តរជាតិ (IOC) ក្រុមប្រឹក្សាអូឡាំពិកអាស៊ី (OCA) សហព័ន្ធកីឡាអន្តរជាតិ (IFs) ក្រុមប្រឹក្សាស៊ីហ្គេម (SEAGF Council) និងអង្គការកីឡាអន្តរជាតិដទៃទៀតប្រមាណ៣០០០នាក់។

**៣-បញ្ហាផ្សេងៗ** ៖ អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូន «**កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលហុងគ្រី ស្តីពីការជំរុញ និងការការពារទៅវិញ ទៅមកនៃវិនិយោគ**» ទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ។

ជាចុងក្រោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានណែនាំ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋ ពេលដែលប្រទេសកម្ពុជាបាន និងកំពុងទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ ខ្យល់កន្ត្រាក់ រលកកំដៅដោយធ្វើការផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋដែលខ្វះខាតទឹកប្រើប្រាស់ និងបានអំពាវនាវឲ្យប្រជាពលរដ្ឋសន្សំសំចៃចំពោះការប្រើប្រាស់ទឹកផងដែរ។
- ធ្វើការចែកជូនអាវភ្លៀងដល់កងកំលាំងប្រដាប់អាវុធដែលកំពុងឈរជើងនៅតាមទិសសំខាន់ៗ នៃប្រទេស និងខ្សែបន្ទាត់ព្រំដែនឲ្យបានរួចរាល់ក្នុងខែឧសភា ឆ្នាំ ២០១៦ នេះ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១១ និង ៣០នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦